CITY OF
LONG BEACH

# ធនធានទីក្រុង

## ជំនួយ ផ្នែកលំនៅដ្ឋាន

### *កម្មវិធីជំនួយថ្លៃឈ្នួលផ្ទះបន្ទាន់ក្រុងឡុងប៊ិច*

*មានផ្តល់ជូនសម្រាប់ប្រជាពលរដ្ឋ ដែលគ្មានឯកសារបញ្ជាក់ – មានព័ត៌មាន នៅលើគេហទំព័រ ជាភាសាអេស្ប៉ាញ ភាសាខ្មែរ និងភាសាតាហ្គាឡុក*

- កម្មវិធីជំនួយថ្លៃឈ្នួលផ្ទះបន្ទាន់ក្រុងឡុងប៊ិច (LB-ERAP) ត្រូវបានរចនាបង្កើតឡើង ដើម្បីជួយ អ្នកជួលផ្ទះមានកម្រិតចំណូល ដែលអាចមានសិទ្ធិទទួលបាន (អ្នកជួលផ្ទះ) និងម្ចាស់ផ្ទះ-ដី ដែលពើបប្រទះការខាតបង់ ផ្នែកហិរញ្ញវត្ថុ ឬការលំបាក ដោយសារ COVID-19 តាមរយៈជំនួយថ្លៃឈ្នួលផ្ទះ ។
- LB-ERAP ត្រូវបានបង្កើតឡើង ដើម្បីផ្តល់ជំនួយដាច់មុខ ដល់ម្ចាស់ផ្ទះ-ដី និងអ្នកជួលផ្ទះ នៅឡុងប៊ិច ហើយនៅដាច់ឡែក ពីកម្មវិធីជំនួយថ្លៃឈ្នួលផ្ទះរបស់រដ្ឋ ។ អ្នកដាក់ពាក្យស្នើសុំ មិនគួរដាក់ពាក្យ ទៅកម្មវិធីរបស់រដ្ឋនោះទេ ប្រសិនបើផ្ទះរបស់ខ្លួនដែលកំពុងស្វែងរកជំនួយបង់ថ្លៃនោះ មានទីតាំង ស្ថិតនៅក្នុងទីក្រុងនេះ ។
- LB-ERAP នឹងជួយអ្នកជួលផ្ទះមានកម្រិតចំណូល ដែលអាចមានសិទ្ធិទទួលបាន បង់ថ្លៃឈ្នួលផ្ទះ និងថ្លៃសេវាបម្រើជីវភាព (utilities) ទាំងថ្លៃមិនទាន់បានទូទាត់ពីមុនមក និងថ្លៃនាពេលអនាគត ។ កម្មវិធីនឹងកំណត់អាទិភាព លើការជួយដល់ អ្នកជួលផ្ទះមានកម្រិតចំណូលទាប ដែលគ្មានការងារធ្វើ ក្នុងរយៈពេល 90 ថ្ងៃ ឬ ច្រើនជាងនេះ និងដែលប្រឈមមហានិភ័យអស្ថេរភាព ផ្នែកលំនៅដ្ឋាន ។
- ឯកសារទាំងអស់ របស់កម្មវិធី រួមទាំង សិទ្ធិអាចទទួលផល ពីកម្មវិធីបាននោះ អាចរកបាន នៅលើអ៊ីនធឺណែត នៅ longbeach.gov/rentalassistance ។ គេហទំព័រនេះ មានបម្រើជូន ជាភាសាអេស្ប៉ាញ ភាសាខ្មែរ និងភាសាតាហ្គាឡុក ។
- **អំឡុងពេលដាក់ពាក្យស្នើសុំ នៅបើកនៅឡើយ រហូតទាល់តែអស់មូលនិធិ ។ សម្រាប់ចម្ងល់ ឬបច្ចុប្បន្នភាព អំពីពាក្យស្នើសុំ សូមចូលទៅ ច្រកដាក់ពាក្យស្នើសុំ ឬ ទូរសព្ទទៅ បណ្តាញព័ត៌មាន & ការគាំទ្រ របស់ LB-ERAP ដែលចាត់ចែង ដោយប្រព័ន្ធ យ៉ាឌី (Yardi Systems) ជាដៃគូកម្មវិធី របស់សាលាក្រុង តាមរយៈលេខ (833) 358-5372 ដែលផ្តល់ការគាំទ្រ ដោយប្រើ ភាសាអង់គ្លេស និងភាសាអេស្ប៉ាញ នៅថ្ងៃចន្ទ – ថ្ងៃសុក្រ ពីម៉ោង 8 ព្រឹក ដល់ម៉ោង 6 យប់ ។**

### *កម្មវិធីអភិវឌ្ឍន៍លំនៅដ្ឋានថ្លៃសមរម្យ ដែលអាចបើកដំណើរការ*

**សម្រាប់បញ្ជីឯកតាផ្ទះ ដែលមានថ្លៃសមរម្យ នៅឡុងប៊ិច សូមចុចលើ ៖**
https://www.longbeach.gov/globalassets/lbds/media-library/documents/housing--neighborhood-services/affordable-housing-list-2021

លំនៅដ្ឋានទាំងនេះ មានកាន់កាប់ ជាចំបង ដោយឯកជន ហេតុនេះ សាលាក្រុងគ្មានព័ត៌មាន អំពីផ្ទះអាចរកជួលបាន ឬដំណើរការដាក់ពាក្យស្នើសុំ ដែលមានតម្រូវនោះទេ ។ លោកអ្នកត្រូវបាន លើកទឹកចិត្ត ឱ្យទាក់ទងទៅ លំនៅដ្ឋាននីមួយៗ ដើម្បីដឹង អំពីថ្លៃ និងផ្ទះអាចរកជួលបាន ។

### *សិទ្ធិទទួលបាន ការប្រឹក្សា ផ្នែកច្បាប់សម្រាប់អ្នកជួលផ្ទះ*

សាលាក្រុងបានប្តេជ្ញា ផ្តល់មូលនិធិថ្មី ដើម្បីគាំទ្រដល់ សិទ្ធិទទួលបាន ការប្រឹក្សាផ្នែកច្បាប់ និង ជំនួយថ្លៃឈ្នួលផ្ទះ ជូនដល់អ្នកជួលផ្ទះ នៅឡុងប៊ិច តាមរយៈ កម្មវិធីរក្សាទីជម្រកបាន ខោនធី ឡូស អ៊ែន ជឺឡេស (Stay

Housed LA County Program) ។ កម្មវិធីនេះផ្តល់ សេវាច្បាប់ ក្នុងលក្ខណៈដែលអ្នកមកមុន ទទួលបានមុន និង ជំនួយថ្លៃឈ្នួលផ្ទះ រយៈពេលខ្លី ដល់អ្នកជួលផ្ទះមានកម្រិតចំណូល ដែលអាចមានសិទ្ធិទទួលបាន ។

ធនធានរួមមាន ៖

- កម្មវិធីផ្សព្វផ្សាយ និងអប់រំ អ្នកជួលផ្ទះ ដើម្បីជូនដំណឹង ដល់អ្នកជួលផ្ទះ អំពីសិទ្ធិរបស់ពួកគេ និងសេវានានា ដែលមានផ្តល់ជូន តាមរយៈកម្មវិធី Stay Housed LA ។
- លទ្ធភាពទទួលបាន សេវាគាំទ្រពាក់ព័ន្ធនានា ដើម្បីជួយ ឯកត្តជន និងក្រុមគ្រួសារ ដែលធ្លាក់ខ្លួនបាត់បង់ទីជម្រក ។

**សម្រាប់ព័ត៌មាន បន្ថែមទៀត សូមចូលទៅ គេហទំព័រ របស់កម្មវិធី Stay Housed LA នៅ ៖ https://www.stayhousedla.org/ ឬដើម្បីទទួលបានជំនួយបន្ទាន់ សូមទូរសព្ទទៅលេខ ៖ (888) 694-0040 ដែលប្រើ ភាសាអង់គ្លេស និងភាសាអេស្ប៉ាញ ។ សម្រាប់ភាសាផ្សេងៗ ទៀត សូមទូរសព្ទទៅលេខ (833) 225-9415 ។**

# ផ្នែក 8

អាជ្ញាធរលំនៅដ្ឋានក្រុងឡុងប៊ិច (HACLB) ប្រតិបត្តិការកម្មវិធីជំនួយថ្លៃឈ្នួលផ្ទះ របស់សាលាក្រុង រួមទាំង សក្ខីបត្រ របស់ផ្នែក 8ផងដែរ ។ កម្មវិធីជំនួយទាំងនេះ ត្រូវបានរចនាបង្កើតឡើង ដើម្បីផ្តល់ជំនួយ ហិរញ្ញវត្ថុ និងជំនួយបច្ចេកទេស ជូនដល់ ប្រជាពលរដ្ឋឡុងប៊ិច ដែលមាន កម្រិតចំណូលទាប ជាជនវ័យចាស់ និង ជាជនពិការ ដើម្បីឱ្យពួកគេអាចរស់នៅបាន ប្រកបដោយសេចក្តីថ្លៃថ្នូរ ក្នុងស្ថានភាពលំនៅដ្ឋានសមរម្យ មានសុវត្ថិភាព និងអនាម័យ ។

នាពេលបច្ចុប្បន្ននេះ HACLB ដោយសហការជាមួយ ម្ចាស់ផ្ទះជាង 2,600 ទីតាំង ផ្តល់ជំនួយដល់ ប្រជាពលរដ្ឋ ជាង 6,800 គ្រួសារ ដែលជួលផ្ទះរស់នៅ ក្នុងទីក្រុងឡុងប៊ិច តាមរយៈកម្មវិធីផ្សេងៗ ។

HACLB ក៏ផ្តល់សេវាគាំទ្រពិសេស ដល់ក្រុមគ្រួសារនានាផងដែរ តាមរយៈ កម្មវិធីស្វ័យគ្រប់គ្រាន់ សម្រាប់គ្រួសារ និងកម្មវិធីកម្មសិទ្ធិផ្ទះ ។ កម្មវិធីទាំងនេះផ្តល់ ការបណ្តុះបណ្តាល ផ្នែកហិរញ្ញវត្ថុ និងអក្ខរកម្ម, ការបង្កើត គណនីគ្រប់គ្រងដោយភាគីទីបី, មគ្គុទេសក៍ ផ្នែកអាជីព និងការសិក្សា, និង ធនធានបញ្ជូលបន្ត ។ ការបណ្តុះ បណ្តាលការងារក៏មានផ្តល់ជូន តាមរយៈ កម្មវិធីភាពជាដៃគូ ជាមួយការិយាល័យអភិវឌ្ឍន៍កម្លាំងពលកម្ម របស់សាលាក្រុង ដើម្បីជួយបន្ថែមទៀត ក្នុងការទ្រទ្រង់គ្រួសារនានារបស់យើង ឱ្យអាចឈានទៅសម្រេចបាន ភាពស្វ័យគ្រប់គ្រាន់ ផ្នែកសេដ្ឋកិច្ច ហើយអាចមានកម្មសិទ្ធិផ្ទះបាន ផងដែរ ។

*នាពេលបច្ចុប្បន្ននេះ បញ្ជីរង់ចាំសក្ខីបត្រជម្រើសលំនៅដ្ឋាន (ផ្នែក 8) ត្រូវបានបិទបញ្ចប់ហើយ ។*

សម្រាប់ព័ត៌មាន បន្ថែមទៀត សូមកុំរារែក នឹងចូលទៅគេហទំព័រ ៖ https://www.longbeach.gov/haclb/

**អាជ្ញាធរលំនៅដ្ឋាន ចាប់បើកដំណើរឡើងវិញ ក្នុងការទទួលការណាត់ជួប ផ្ទាល់ ដោយមានចំនួនកំណត់ នៅ ៖ អាសយដ្ឋានលេខ 1500 ផ្លូវហាហ្វស៍ (Hughes Way), #A-150, ឡុងប៊ិច, CA 90810 សម្រាប់ព័ត៌មាន បន្ថែមទៀត សូមទូរសព្ទទៅលេខ ៖ (562) 570-6985.**

# ជំនួយ ផ្នែកសេវាបម្រើជីវភាព (Utility Assistance)

*នាយកដ្ឋានធនធានថាមពល*

នាយកដ្ឋានថាមពល ឡុងប៊ិច (LBER) ផ្តល់ ការបញ្ចុះថ្លៃ 20% លើវិក្កយបត្រឧស្ម័ន ប្រចាំខែ សម្រាប់ គ្រួសារ ដែលមានសិទ្ធិអាចទទួលបាន, ផែនការរៀបចំការទូទាត់ប្រាក់ និង កម្មវិធីលើកលែងពន្ធអ្នកប្រើប្រាស់សេវាបម្រើជីវភាព ព្រមទាំង ការបញ្ចុះថ្លៃ បន្ថែមទៀត សម្រាប់អតិថិជន ជាជនវ័យចាស់ និង ជនពិការ ។

- **សម្រាប់ព័ត៌មាន បន្ថែមទៀត សូមចូលទៅគេហទំព័រ ៖ https://www.longbeach.gov/utilityservices/billing-and-payments/utility-assistance/ ឬ ទូរសព្ទទៅលេខ ៖ (562) 570-5700**

*ដើម្បីដាក់ពាក្យដោយផ្ទាល់ សូមមើលផ្នែកខាងក្រោមនេះ ៖*

ទាញយក / បោះពុម្ព ពាក្យស្នើសុំ ដែលមានផ្តល់ជូន ជា ភាសាអង់គ្លេស និង ភាសាអេស្ប៉ាញ ឬ លោកអ្នកអាចដាក់ ពាក្យស្នើសុំ តាមអ៊ីនធឺណែត នៅ ៖ https://forms.longbeach.gov/Forms/GasDiscount ។ **លោកអ្នកក៏អាចទទួលបាន ពាក្យស្នើសុំ តាមរយៈការទូរសព្ទទៅលេខ (562) 570-2068 បានផងដែរ ។** ពាក្យស្នើសុំគួរត្រូវបញ្ជូនត្រឡប់ទៅ អាសយដ្ឋាន ដូចមានរាយបញ្ជាក់ នៅក្នុងពាក្យស្នើសុំនោះ ។

## *នាយកដ្ឋានទឹក ឡុងប៊ិច*

ភាពជាដៃគូសកម្មភាពសហគមន៍ ឡុងប៊ិច **(LBCAP)** បានកំពុងសហការជាមួយ នាយកដ្ឋានទឹក ឡុងប៊ិច ដើម្បីផ្តល់ជំនួយហិរញ្ញវត្ថុផ្ទាល់ជូន **គ្រួសារដែលមានចំណូលទាប នាពេលបច្ចុប្បន្ននេះ** សម្រាប់ដោះស្រាយចំណាយលើថ្លៃទឹករបស់ពួកគេ ដែលមានបន្ទុកកើនឡើង ក្នុងអំឡុងពេលមានវិបត្តិឆ្លង COVID-19 រាតត្បាតជាសាកលនេះ ។

*អតិថិជន របស់នាយកដ្ឋានទឹក ឡុងប៊ិច (LBWD) ដែលមានគុណវុឌ្ឍន៍គ្រប់គ្រាន់ អាចទទួលបាន ៖*

- អត្ថប្រយោជន៍ផ្តល់ជូន តែម្តង ជាទឹកប្រាក់ចំនួន $200
- ទូទាត់ជូនទៅ LBWD ហើយផ្ទេរចូល ទៅគណនីរបស់លោកអ្នក ផ្ទាល់ តែម្តង
- ការផ្តល់មូលនិធិដល់កម្មវិធី ជាទឹកប្រាក់មានកម្រិត ហើយមានផ្តល់ជូន ក្នុងលក្ខណៈអ្នកមកមុន ទទួលបានមុន ។

*អ្នកដែលមានសិទ្ធិអាចទទួលបាន (ត្រូវបំពេញបាន លក្ខខណ្ឌតម្រូវ ទាំងបី) ៖*

- ជាពលរដ្ឋ ដែលមានវិក្កយបត្រទឹក នៅឡុងប៊ិច ដាក់ឈ្មោះខ្លួនឯង និង
- មកពីគ្រួសារ បំពេញបានលក្ខខណ្ឌកម្រិតចំណូល ដែលអាចមានសិទ្ធិទទួលបាន **(សូមមើល គោលការណ៍ណែនាំ ស្តីពីភាពក្រីក្រឆ្នាំ 2021 របស់សហព័ន្ធ)**, និង
- មកពីគ្រួសារដែលរងផលជះ អវិជ្ជមានពី COVID-19

**ដើម្បីដឹងថា លោកអ្នកអាចមានគុណវុឌ្ឍន៍គ្រប់គ្រាន់ សម្រាប់កម្មវិធីណាខ្លះនោះ សូមចូលគេហទំព័រ ៖ https://lbwater.org/waterbillprogram/ ឬ ទូរសព្ទទៅលេខ ៖ (562) 216-4614**

## សេវាជនគ្មានទីលំនៅ

នាពេលបច្ចុប្បន្ននេះ ប្រសិនបើលោកអ្នក ឬ ជនណាម្នាក់ ដែលលោកអ្នកស្គាល់ មានបញ្ហាខ្វះទីជម្រក ឬ ឈានចូលដំណាក់កាល ជិតមានបញ្ហាខ្វះទីជម្រកនោះ សូមចូលទៅ មជ្ឈមណ្ឌលពហុសេវា (MSC) ៖

នៅអាសយដ្ឋានលេខ 1301 វិថី W. 12th
ឡុងប៊ិច កាលីហ្វ័រញ៉ា 90813

លេខទូរសព្ទ ៖ (562) 570-4500
បណ្ដាញលេខផ្នែកផ្សព្វផ្សាយ តាមផ្លូវ ៖ (562) 570-4MSC

- MSC ផ្តល់ជូន សេវាដូចខាងក្រោមនេះ ដល់បុគ្គល និងក្រុមគ្រួសារ ដែលមានបញ្ហាខ្វះទីជម្រក ឬ ឈានចូលដំណាក់កាល ជិតមានបញ្ហាខ្វះទីជម្រក៖ សេវាផ្សព្វផ្សាយ, សេវាទទួលឱ្យចូលកម្មវិធី និងការវាយតម្លៃ, ការគ្រប់គ្រងករណី, ព្រមទាំង ការបញ្ជូន ទៅមណ្ឌលជម្រក និង កម្មវិធីសេវាសង្គមផ្សេងៗ ទៀត ។

| ម៉ោងប្រតិបត្តិការ របស់មជ្ឈមណ្ឌលពហុសេវា ឡុងប៊ិច | |
|---|---|
| ថ្ងៃក្នុងសប្តាហ៍ | ម៉ោង (កំណត់សម្គាល់ ៖ MSC បិទ នៅម៉ោង 12:00 ថ្ងៃត្រង់ - 1:00 រសៀល ជារៀងរាល់ថ្ងៃ |
| ថ្ងៃចន្ទ | 8:00 ព្រឹក - 4:00 រសៀល |
| ថ្ងៃអង្គារ | 8:00 ព្រឹក - 4:00 រសៀល |
| ថ្ងៃពុធ | 8:00 ព្រឹក - 4:00 រសៀល |
| ថ្ងៃព្រហស្បតិ៍ | 8:00 ព្រឹក - 2:00 រសៀល |
| ថ្ងៃសុក្រ | 8:00 ព្រឹក - 4:00 រសៀល |

# ការងារ ការគាំទ្រ ដល់ធុរកិច្ច & ការអភិវឌ្ឍសេដ្ឋកិច្ច

## *ធនធាន សម្រាប់ធុរកិច្ច និងបុគ្គលិក-ពលករ*

សម្រាប់ការគាំទ្រ ដល់ធុរកិច្ច និងបុគ្គលិក-ពលករ ពាក់ព័ន្ធនឹង COVID-19 សូមទាក់ទងទៅ បណ្ដាញទាន់ហេតុការណ៍ និង មជ្ឈមណ្ឌលទូរសព្ទ តាមរយៈលេខ **(562) 570-4BIZ (4249),** ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ នៅម៉ោង 8 ព្រឹក - 5 ល្ងាច ។ មន្ត្រីសាលាក្រុង នឹងឆ្លើយតប ទៅនឹងសារសម្លេង ដែលមានបញ្ជូន ក្រោយម៉ោងធ្វើការ ក្នុងរយៈពេល 24 ម៉ោង ។

- **ធនធាន សម្រាប់ធុរកិច្ច ៖** https://longbeach.gov/economicdevelopment/covid-19-business-support/business-resources/
    - កម្មវិធីទីតាំងជំនួយចល័ត BizCare mobile pop-ups មានផ្តល់ជូន ធុរកិច្ច ខ្នាតតូចទាំងអស់ នៅឡុងប៊ិច និងមានផ្តោត ចំពោះធុរកិច្ច នៅតាមសហគមន៍ដែលរងផលជះ ខ្លាំងបំផុត ពីបញ្ហាឆ្លងរោគរាតត្បាតជាសាកលនេះ ។ ទីតាំងជំនួយចល័តនេះ ផ្តល់ជូនការគាំទ្រ ឥតគិតថ្លៃ ជាការពិគ្រោះតទល់ ដោយផ្ទាល់ ដល់ម្ចាស់ធុរកិច្ច ឬ តំណាង របស់ពួកគេ ដើម្បីបំពេញពាក្យស្នើសុំជំនួយឥតសំណង ពីថ្នាក់មូលដ្ឋាន, អង្គការមិនរកប្រាក់ចំណេញ, ថ្នាក់រដ្ឋ និងថ្នាក់សហព័ន្ធ ។ ធុរកិច្ច ទទួលបាន ធនធានសហគមន៍ ដូចជាកម្ចី និង ជំនួយបច្ចេកទេស ដោយឥតគិតថ្លៃ ។ សេវាកម្មបកប្រែ ពហុភាសា អាចរកបាន នៅនឹងកន្លែងនីមួយៗ ។

**BizCare Pop-ups**

**Monday August 24, 2020 to Friday December 31, 2021**

| DAY | LOCATION | ADDRESS | TIME |
|---|---|---|---|
| MON | Admiral Kidd Park | 2125 Santa Fe Ave | 9am-4pm |
| TUES | Michelle Obama Library | 5870 Atlantic Ave | 9am-4pm |
| WED | Michelle Obama Library | 5870 Atlantic Ave | 9am-4pm |
| NEW LOCATION ADDED! Opens July 7 | | | |
| WED | The Corner Pop-up | 2640 E Anaheim St | 9am-4pm |
| THURS | Mark Twain Library | 1401 E Anaheim St | 9am-4pm |

- **ធនធានសម្រាប់បុគ្គលិក-ពលករ ៖** https://longbeach.gov/economicdevelopment/covid-19-business-support/worker-resources/
    - កន្លែងការងារ (មជ្ឈមណ្ឌលការងារ) បើកបម្រើការ និងជួយ ក្រុមគ្រួសារ បុគ្គលិក-ពលករ និងធុរកិច្ចនានា ដែលរងផលជះ ពី COVID-19 នៅឡុងប៊ិច ។ មជ្ឈមណ្ឌលការងារ គ្រប់គ្រងដោយ បណ្ដាញនវានុវត្តន៍កម្លាំងពលកម្ម ប្រេកប៉ាស៊ីហ្វិក (Pacific Gateway) ។
    - **ដើម្បីទាក់ទងទៅបាន សូមចូលទៅ គេហទំព័រ ៖ https://www.pacific-gateway.org/ ឬ ទូរសព្ទទៅលេខ (562) 570-3700 ។**

# ធនធានសហគមន៍បន្ថែមទៀត

## មូលនិធិជំនួយ ផ្លូវច្បាប់របស់ឡូស អ៊ែន ជឺឡេស (LAFLA)

LAFLA ផ្ដល់សេវា ពាក់ព័ន្ធនឹង ៖

- ការការពារមិនឱ្យបណ្ដេញចេញ / លំនៅដ្ឋាន (រៀបចំដោយ អាជ្ញាធរ តំបន់ / ក្រុង)
- កិច្ចគាំពារអ្នកជួល - សំណួរមានចោទឡើងច្រើន (រៀបចំដោយ អាជ្ញាធរ តំបន់ / ក្រុង)
- អត្ថប្រយោជន៍ ពីរដ្ឋាភិបាល
- អ្នកជួលផ្ទះ បម្រើឱ្យពាណិជ្ជកម្ម
  - **សម្រាប់ព័ត៌មាន បន្ថែមទៀត សូមទូរសព្ទទៅ មូលនិធិជំនួយ ផ្លូវច្បាប់ របស់ឡូស អ៊ែន ជឺឡេស តាមរយៈលេខ ៖** (800) 399-4529 ឬចូលទៅ longbeach.gov/haclb/news/fair-housing-visiting-the-haclb/

## សកម្មភាពបំបាត់ភាពអត់ឃ្លាន ឡូស អ៊ែន ជឺឡេស (Hunger Action LA)

សកម្មភាពបំបាត់ភាពអត់ឃ្លាន ឡូស អ៊ែន ជឺឡេស (HALA) ធ្វើការ ដើម្បីបញ្ចប់ភាពអត់ឃ្លាន និងលើកកម្ពស់ការទទួលទាន ប្រកបដោយសុខភាព តាមរយៈការតស៊ូមតិ ការផ្ដល់សេវាផ្ទាល់ និង ដំណើរការរៀបចំ ។

ព័ត៌មាន អំពីរបៀប ដែលប្រជាពលរដ្ឋអាចទទួលបាន អាហារ ប្រាក់ លំនៅដ្ឋាន ការថែទាំសុខភាព និងលទ្ធភាពទទួលបានផល ពីកម្មវិធី និងសេវាសហគមន៍ផ្សេងៗ ទៀត របស់រដ្ឋាភិបាល នៅខោនធីឡូស អ៊ែន ជឺឡេស ៖

- មគ្គុទេសក៍ សម្រាប់ប្រជាពលរដ្ឋ ស្ដីពីសេវាសុខមាលភាព សេវាសុខភាព និងសេវាផ្សេងៗ ទៀត
- មគ្គុទេសក៍ សម្រាប់ប្រជាពលរដ្ឋ ស្ដីពីសេវាសុខមាលភាព សេវាសុខភាព និងសេវាផ្សេងៗ ទៀត (ភាសាអេស្ប៉ាញ)

## មូលនិធិលំនៅដ្ឋានសមភាព

មូលនិធិលំនៅដ្ឋាន សមរម្យ ធ្វើការងារ ដើម្បីលុបបំបាត់ ការរើសអើង ផ្នែកលំនៅដ្ឋាន និងលើកកម្ពស់ លទ្ធភាពទទួលបាន ប្រកបដោយសមភាព ចំពោះជម្រើសលំនៅដ្ឋាន សម្រាប់អ្នកគ្រប់គ្នា ។ ផ្នែកខ្លះ នៃសេវារបស់ពួកគេ រួមមាន ៖

- ការផ្ដល់ប្រឹក្សា សម្រាប់ម្ចាស់ផ្ទះ-ដី & អ្នកជួល
- ការផ្ដល់ប្រឹក្សាអំពីការជួលផ្ទះ
- ការផ្សព្វផ្សាយ & ការអប់រំ

- **អាសយដ្ឋាន ៖** 3605 មហាវិថីឡុងប៊ិច, Ste. អាសយដ្ឋានលេខ 302, ឡុងប៊ិច, CA 90807
- **លេខទូរសព្ទ** ៖ (562) 989-1206 ឬ (800) 466-3247 ។
- **គេហទំព័រ ៖** https://fhfca.org/